KHMER

# 3 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ
## ប្រព័ន្ធប្រើប្រាស់ទឹកឡើងវិញ

នៅក្រោមច្បាប់បរិដ្ឋានរដ្ឋញូវសៅវែល លោកអ្នកមិនត្រូវឲ្យជាតិគីមី ហើយនិងទឹកក្រខ្វក់ហូរចូលទៅក្នុងប្រព័ន្ធទឹកស្អាត ឬហូរចេញពីដីធ្លីរបស់លោកអ្នកឡើយ បើពុំដូច្នោះទេនោះ លោកអ្នកត្រូវគេផាកពិន័យយ៉ាងធ្ងន់ ឬត្រូវបង់ពិន័យយ៉ាងច្រើន ឬជាប់ពន្ធនាគារ។ ទោះជាយ៉ាងណាក៏ដោយ លោកអ្នកអាចបង្កើតប្រព័ន្ធប្រើប្រាស់ទឹកឡើងវិញនៅក្នុងចំការរបស់លោកអ្នក ដែលអាចជួយឲ្យលោកអ្នកសន្សំប្រាក់ច្រើនតាមរយៈ:

- ការបង្កើនភោគផលរបស់លោកអ្នក
- កាត់បន្ថយនូវការប្រើប្រាស់ទឹក ឬការប្រើប្រាស់ជាតិគីមី
- ការកែលំអការគ្រប់គ្រងជម្ងឺដំណាំ
- កាត់បន្ថយនូវការទទួលខុសត្រូវតាមផ្លូវច្បាប់របស់លោកអ្នក។


NSW DPI, Virginia Brunton

**ការធ្វើប្រព័ន្ធនេះត្រូវការការអនុញ្ញាតយល់ព្រមពីសាលាក្រុង ហើយអាចមានតម្លៃប្រហែលជា ១០,០០០ដុល្លា (ដោយប្រើអ្នកអាជីពដែលមានសញ្ញាប័ត្រ)។**


NSW DPI, Steven Honeywood

មានប្រព័ន្ធមួយចំនួនដែលលោកអ្នកអាចប្រើ។ ប្រព័ន្ធមួយគឺសំរាប់ទប់ទឹកហូរចេញពីចំការ ហើយទប់ និងសំអាតដោយពំនូកដើមត្រែង ឬដើមប្របុស ឬច្រោះតាមខ្សាច់។ ពំនូកដើមត្រែង ឬដើមប្របុសបំផ្លាញជាតិគីមី និងមេរោគ។ ទឹកច្រោះនោះអាចគេយកទៅប្រើប្រាស់ក្នុងចំការ ដែលអាចជួយកាត់បន្ថយលើការចំណាយ។ លោកអ្នកអាចប្រើប្រាស់ទឹកដែលទប់បាននេះឡើងវិញ ដើម្បីយកទៅស្រោចបន្លែ ឬចំការ។ លោកអ្នកត្រូវការឃ្លាំមើលឲ្យបានញឹកញាប់នៃកំរិតជាតិបំប៉ន និងជម្ងឺដែលបណ្តាលឲ្យកើតសរីរាង្គទាំងឡាយ។

ប្រព័ន្ធប្រើប្រាស់ទឹកឡើងវិញនេះមានបីផ្នែកយ៉ាងសំខាន់:

- ការទប់ទឹក
- ការច្រោះដោយពំនូកដើមត្រែង ឬដើមប្របុស
- ទប់យកទឹកដែលហូរចេញ ហើយយកមកប្រើវិញ

### ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទូរស័ព្ទ:

ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល លេខ 02 4588 2107។

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា TIS សូមទូរស័ព្ទលេខ 131 450។

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST